# កិច្ចសន្យាប្រមូលសាច់ប្រាក់

**រវាង**

**លោក/លោកស្រី** ......អ៊ុន រតនៈ...... **តំណាងអោយ ធនាគារ អេស៊ីលីដា ភីអិលស៊ី** ការិយាល័យកណ្តាល **ដែលមានទីតាំងនៅ**......អាគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ភ្នំពេញ...... **ទូរស័ព្ទ** 023 324 444......
**ទូរសារ**.023 324 444.......... **តទៅនេះហៅថា ភាគី "ក" ។**

**និង**

**លោក/លោកស្រី** .....អាំ ច័ន្ទពិសិដ្ឋ...... **តំណាងអោយក្រុមហ៊ុន/ស្ថាប័ន** ........Fresh Internet......... **ចុះបញ្ជីលេខ**......XXXXX......
**ចេញដោយ**......ក្រសួងពាណិជ្ជកម្ម............ **នៅថ្ងៃទី**......01/10/2013......... **ដែលមានទីតាំងបច្ចុប្បន្ន**.#39BEo......
...St. 146, PP.................................................... **ទូរស័ព្ទ**.078 789 788....... **ទូរសារ**....023 789 788.......,
**តទៅនេះហៅថា ភាគី "ខ" ។**

**ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងគ្នាទៅលើ សេវាប្រមូលសាច់ប្រាក់ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖**

1. ភាគី "ខ" ព្រមព្រៀងប្រើប្រាស់សេវាប្រមូលសាច់ប្រាក់ (Cash Collection) របស់ភាគី "ក" ។
2. ភាគី "ខ" ព្រមព្រៀងបើកគណនី : ☑គណនីចរន្ត ☐គណនីសំចៃ ☐គណនីសន្សំតាមតំរូវការ, ឈ្មោះគណនី : Fresh Internet............ លេខគណនី : 0100 10 366666 66, និងឯកភាព រាល់នីតិវិធីទាំងឡាយនៃការប្រើប្រាស់គណនី របស់ភាគី "ក" ។
3. ភាគី "ក" ព្រមព្រៀងទទួលយកវិក្កយបត្រ និងប្រមូលសាច់ប្រាក់ពីអ្នកបង់ប្រាក់ របស់ ភាគី "ខ" នៅការិយាល័យធនាគារអេស៊ីលីដា ភីអិលស៊ី ដែលមានអាសយដ្ឋាន ដូចបានរៀបរាប់ខាងលើ ។ ពេលវេលាទទួលប្រាក់ គឺនៅរៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ វេលាម៉ោង 7:30 ព្រឹក ដល់ម៉ោង 16:00 រសៀល ដោយមិនរាប់បញ្ចូលថ្ងៃឈប់សំរាកសំរាប់បុណ្យសាធារណៈ ។
4. ភាគី "ខ" ត្រូវទទួលខុសត្រូវលើការជូនដំណឹងដល់អ្នកបង់ប្រាក់ អំពីការមកបង់ប្រាក់នៅការិយាល័យធនាគារ អេស៊ីលីដា ភីអិលស៊ី ទៅតាមពេលវេលាបង់ប្រាក់ជាក់លាក់ណាមួយ និងនៅចន្លោះពេលដូចមាន ចែងក្នុងចំណុច 3 ខាងលើ ។
5. ភាគី "ខ" ត្រូវទទួលខុសត្រូវធ្វើអោយប្រាកដថា ការបង់ប្រាក់របស់អ្នកបង់ប្រាក់ ត្រូវបានធ្វើឡើងទៅតាម កាលកំណត់ ហើយចំនួនទឹកប្រាក់ដែល ភាគី "ក" ត្រូវទទួល សមមូលទៅនឹងចំនួនទឹកប្រាក់ ដែលស្តែងឡើងនៅលើវិក្កយបត្របង់ប្រាក់របស់អ្នកបង់ប្រាក់ ។
6. ភាគី "ក" ត្រូវចេញបង្កាន់ដៃទទួលប្រាក់អោយទៅអ្នកបង់ប្រាក់ ឬបញ្ជាក់ពីការទទួលប្រាក់លើវិក្កយបត្រ ហើយរក្សាកន្ទុយវិក្កយបត្រទុក បន្ទាប់ពីបានទទួលប្រាក់ដែលត្រូវបង់គ្រប់ចំនួន ។
7. ភាគី "ខ" ព្រមព្រៀងបង់ថ្លៃសេវាប្រមូលសាច់ប្រាក់ អោយទៅភាគី "ក" ទៅតាមអត្រាដូចខាងក្រោម ៖
   ថ្លៃសេវា = ចំនួនវិក្កយបត្របង់ប្រាក់របស់អ្នកបង់ប្រាក់គុណនឹង $ ....0.25..... ជាអក្សរ (..........ម្ភៃប្រាំសេន.............) ។
8. ភាគី "ក" មិនទទួលខុសត្រូវលើការតាមទារប្រាក់ពីអ្នកបង់ប្រាក់ឡើយ ក្នុងករណីដែលអ្នកបង់ប្រាក់ខកខានមិនបានបង់ប្រាក់ទៅតាមកាលកំណត់ ឬក៏បង់ប្រាក់មិនគ្រប់ចំនួនតាមវិក្កយបត្របង់ប្រាក់ ។
9. ភាគី "ខ" ត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់ភាគី "ក" ក្នុងករណីដែលចង់បញ្ឈប់ការប្រើប្រាស់សេវាប្រមូលសាច់ប្រាក់នេះក្នុងពេលវេលាសមស្របណាមួយជាក់លាក់ ។
10. ភាគី "ក" ត្រូវបញ្ឈប់ការទទួលប្រាក់បង់ ទៅតាមពេលវេលាកំណត់ ដែលភាគី "ខ" បានជូនដំណឹង ។
11. កិច្ចសន្យានេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខារបស់ភាគីទាំងពីរតទៅ ។

ថ្ងៃទី............/ ............ / ............
**ហត្ថលេខា និងត្រា ភាគី "ក"**

ថ្ងៃទី ..01......./ ..10...... / 2013......
**ហត្ថលេខា និងត្រា ភាគី "ខ"**



អាំ ច័ន្ទពិសិដ្ឋ

Form: 50-121